# ព្រឹត្តិបត្រព័ត៌មាន NEC BULLETIN គ.ជ.ប

លេខ ០១ ចេញផ្សាយថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៣


## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ 2013

នៅថ្ងៃ អាទិត្យ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣



ឯកឧត្តម អ៊ឹម សួស្ដី ប្រធាន គ.ជ.ប

**មាតិកា**


- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្ពោធដាក់ឱ្យប្រើប្រាស់....................២
- ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាង គ.ជ.ប មូលនិធិអន្តរជាតិ...........៤
- គ.ជ.ប ជួបពិភាក្សាជាមួយអង្គការជនពិការកម្ពុជា....................................៦
-បទសម្ភាសន៍ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ..............................................៨
- ការងារបោះឆ្នោតត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ............................................១០





necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214 231, Tel: 012 855 018

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័ត៌មានស្តីពីការបោះឆ្នោត




ដើម្បីសម្របសម្រួលនូវការទទួលបានព័ត៌មានទាក់ទងនឹងការបោះឆ្នោត សម្រាប់ប្រជាពលរដ្ឋកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័ត៌មានស្តីពីការបោះឆ្នោត នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ៩:០០ព្រឹក នៅសណ្ឋាគារ អ៊ឹមកើរៀលវីឡា និងហ្គាឌិន រាជធានីភ្នំពេញ ។

តាមរយៈសេវាព័ត៌មាននេះ ប្រជាពលរដ្ឋកម្ពុជាទាំងអស់ នឹងអាចស្តាប់ព័ត៌មានជាមូលដ្ឋានអំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ ដោយគ្រាន់តែធ្វើការហៅទូរស័ព្ទធម្មតាទៅកាន់លេខពិសេស **១២៨៥** ដោយ ឥតគិតថ្លៃ ។



**ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង គ.ជ.ប អញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័ត៌មានស្តីពីការបោះឆ្នោត ឆ្នាំ២០១៣**

ប្រជាពលរដ្ឋហៅទៅកាន់លេខទូរស័ព្ទឥតគិតថ្លៃនេះ នឹងអាចជ្រើសរើសប្រភេទព័ត៌មានដែលខ្លួន



ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប មានប្រសាសន៍ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័តមានស្តីពីការបោះឆ្នោត

ចង់ស្តាប់ ដោយគ្រាន់តែចុចលេខ ១២៨៥ លើទូរស័ព្ទរួចបញ្ជូន ហើយស្តាប់តាមការណែនាំសារជាសំឡេងនោះ ។ សេវាព័ត៌មានស្តីពីការបោះឆ្នោត រួមមាន ព័ត៌មានទាក់ទងនឹងរបៀបនៃការបោះឆ្នោត ពេលវេលាដែលការិយាល័យបោះឆ្នោតនឹងត្រូវបើក ឯកសារដែលត្រូវការសម្រាប់ការបោះឆ្នោត ឬធ្វើយ៉ាងដូចម្តេចដើម្បីឱ្យដឹងថាតើប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតហើយឬនៅ និងថាតើត្រូវទៅបោះឆ្នោតនៅកន្លែងណា ?

ប្រព័ន្ធព័ត៌មានថ្មីនេះប្រើបច្ចេកវិទ្យាមួយដែលហៅថា ប្រព័ន្ធឆ្លើយតបជាសំឡេង (Interactive voice Respone system) ដែលជាប្រព័ន្ធអនុញ្ញាតឱ្យអ្នកប្រើប្រាស់ជ្រើសរើសដោយខ្លួនឯងផ្ទាល់ នូវព័ត៌មានមួយណាដែលខ្លួនចង់ស្តាប់ នៅពេលណា និងទីកន្លែងមួយណាក៏បាន ។

ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់សេវាព័ត៌មាននេះ ត្រូវបានផ្តល់ដោយអង្គការវិទ្យាស្ថានបើកទូលាយ (OI) និងអង្គការមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) បញ្ញត្តករគមនាគមន៍កម្ពុជាព្រមទាំងមានការគាំទ្រពីក្រុមហ៊ុន ផ្តល់សេវាអ៊ីនធើណែត EZECOM និងប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់។ ម្យ៉ាងទៀតការគាំទ្រផ្នែកហិរញ្ញវត្ថុផ្តល់ដោយទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ។

នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័ត៌មានស្តីពីការបោះឆ្នោត ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា៖ ក្រៅពីការផ្តល់ព័ត៌មានអំពីការបោះឆ្នោតតាមរយៈ វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ទូរសារ បដា ខិត្តប័ណ្ណ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឥឡូវនេះយើងនៅមានការផ្តល់ព័ត៌មាន





មន្ត្រី គ.ជ.ប ចូលរួមពីធីសម្ពោធដាក់ឱ្យប្រើប្រាស់សេវាព័តីមានស្តីពីការបោះឆ្នោត

តាមរយៈទូរស័ព្ទចល័តលេខពិសេស ១២៨៥ នេះទៀត ។ ហើយដែលតាមរយៈ លេខពិសេសនេះ លោកអ្នកអាចទទួលព័ត៌មានអំពីការបោះឆ្នោតតាមតម្រូវការ ទោះបីនៅទីណា និងពេលណាក៏ដោយ ៕

# ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាង គ.ជ.ប មូលនិធិអន្តរជាតិសំរាប់ប្រព័ន្ធបោះឆ្នោត និងវិទ្យាស្ថានបើកទូលាយ




**ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (រូបខាងឆ្វេង លោក Robert A.Petterson ប្រធានអង្គការ IFES, រូបកណ្ដាល លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប, រូបខាងស្ដាំ លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិវិទ្យាស្ថានបើកទូលាយ)**

កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) និងវិទ្យាស្ថានបើកទូលាយ(OI) បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានៅសណ្ឋាគារអ៊ុមកើរៀល វីឡា និងហ្គាឌិន នៅរាជធានីភ្នំពេញ។

អនុស្សរណៈយោគយល់គ្នានេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ តម្លាភាពនិងភាពពេញលេញនៅក្នុងការបោះឆ្នោត តាមរយៈការអប់រំអ្នកបោះឆ្នោត ដោយធ្វើយ៉ាងណាឱ្យប្រជាជនទទួលបានព័ត៌មានដោយខ្លួនឯងផ្ទាល់ ដោយប្រើប្រាស់ទូរស័ព្ទចល័តរបស់ខ្លួនតាមរយៈប្រព័ន្ធឆ្លើយតបជាសំឡេង។

ខ្លឹមសារនៃអនុស្សរណៈបានកំណត់ផងដែរអំពីលក្ខខណ្ឌមួយចំនួន ដូចជា៖






រូបថតអនុស្សាវរីយ៍ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាង គ.ជ.ប មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត និងវិទ្យាស្ថានបើកទូលាយ

ការទទួលខុសត្រូវរបស់ភាគីនៃអនុស្សរណៈ ការសម្របសម្រួលការងារ ការទំនាក់ទំនង ថេរវេលានៃការអនុវត្ត ការកែប្រែ និងការបញ្ចប់អនុស្សរណៈជាដើម។

តាមខ្លឹមសារនៃអនុស្សរណៈនេះបានលើកឡើង



តំណាងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមពិធីចុះហត្ថលេខាអនុស្សរណៈយោគយល់គ្នា

ថាអង្គការ (IFES) គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលនាំមុខគេក្នុងការផ្តល់ជំនួយបោះឆ្នោត និងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ។ អង្គការនេះធ្វើការលើកកម្ពស់ស្ថិរភាពលទ្ធិប្រជាធិបតេយ្យ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងតាមការអនុវត្តស្រាវជ្រាវ ដែលទាក់ទងទៅនឹងវដ្តនៃការបោះឆ្នោតនៅក្នុងប្រទេសនានា ជុំវិញពិភពលោក ។

ចំណែកវិទ្យាស្ថានបើកទូលាយ គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលធ្វើលើការងារបង្កើនការប្រើប្រាស់បច្ចេកវិទ្យានិងការទទួលបានព័ត៌មាននៅក្នុងប្រទេស តាមរយៈការប្រើជាភាសាខ្មែរនៅក្នុងបច្ចេកវិទ្យានិងកាត់បន្ថយឧបសគ្គផ្នែកបច្ចេកវិទ្យាក្នុងការទទួលបានព័ត៌មាន ។ អង្គការនេះបានទទួលមូលនិធិពីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងការបង្កើតចែកចាយព័ត៌មានទៅកាន់ប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់ប្រព័ន្ធឆ្លើយតបជាសំឡេង (Interactive Voice Respone System) និងជា

តទៅទំព័រទី ១៨

# គ.ជ.ប ជួបពិភាក្សាជាមួយអង្គការជនពិការកម្ពុជា



**ជំនួបពិភាក្សារវាង គ.ជ.ប ជាមួយអង្គការជនពិការកម្ពុជា**

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ឯកឧត្តម អ៊ឹម សួស្ដី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានអនុញ្ញាតឱ្យលោក ងីន សៅរ័ត្ន ប្រធានអង្គការជនពិការកម្ពុជា និងសហការីចូលជួបសំដែងការគួរសម និងពិភាក្សាពីការចូលរួមបោះឆ្នោតរបស់ជនពិការកម្ពុជា ។

នៅក្នុងជំនួបពិភាក្សានោះលោក ងីន សៅរ័ត្ន បានលើកឡើងពីការងារមួយចំនួនដែលអង្គការជនពិការកម្ពុជាត្រូវពិភាក្សារួមមាន ៖

- ស្នើសុំឱ្យ គ.ជ.ប បង្កើតតារាងមួយនៅលើបញ្ជីបោះឆ្នោតសម្រាប់បង្ហាញឈ្មោះជនពិការ ថាតើមានជនពិការប៉ុន្មាននាក់ចូលរួមបោះឆ្នោត ។
- សុំកិច្ចសហការបណ្ដុះបណ្ដាល ដល់មន្ត្រីបោះឆ្នោត ដើម្បីឱ្យមន្ត្រីបោះឆ្នោតយល់ដឹងថាតើត្រូវធ្វើកិច្ចការជនពិការយ៉ាងដូចម្ដេច និងជួយជនពិការយ៉ាងណា ។

ឯកឧត្តម អ៊ឹម សួស្ដី បានមានប្រសាសន៍ថា នៅថ្ងៃខាងមុខ គ.ជ.ប នឹងត្រូវធ្វើការជ្រើសរើសមន្ត្រី បុគ្គលិកឱ្យចូលបម្រើការងារបោះឆ្នោត ។ ជាទូទៅ គ.ជ.ប តែងតែណែនាំឱ្យធ្វើការជ្រើសរើសស្ត្រីឱ្យបានច្រើនក្នុងការចូលបម្រើការងារបោះឆ្នោត ហើយជនពិការដែលមានលទ្ធភាពធ្វើកិច្ចការនេះបាន ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមផងដែរ ។ ចំពោះការបង្ហាញឈ្មោះជនពិការនៅលើបញ្ជីបោះឆ្នោតសម្រាប់ឆ្នាំនេះ គឺមិនអាចធ្វើបានទេ ពីព្រោះបញ្ជីបោះឆ្នោតត្រូវបានផ្ដល់សុពលភាពរួចរាល់ហើយ

មិនអាចកែប្រែបានទេ ។ ប៉ុន្តែយើងអាចធ្វើកិច្ចការនេះនៅពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៣ ។ ក៏ប៉ុន្តែឯកឧត្តម បានសុំឱ្យអង្គការជនពិការពិភាក្សាជាមួយជនពិការ ថាតើពួកគាត់ចង់បង្ហាញឈ្មោះ ឬយ៉ាងណានៅលើបញ្ជីបោះឆ្នោតនោះ ហើយខាង គ.ជ.ប នឹងពិភាក្សាផ្នែកបច្ចេកទេសបន្ថែមទៀត ថាតើត្រូវដាក់កូឡោនបន្ថែមត្រង់ណា ?



**មន្ត្រី គ.ជ.ប ជំនួបពិភាក្សាជាមួយអង្គការជនពិការកម្ពុជា**

លោក ងិន សៅរ័ត្ន បានជម្រាបជូនឯកឧត្តមប្រធាន គ.ជ.ប ថាបើប្រៀបធៀបទៅនឹងគណៈកម្មាធិការរៀបចំការបោះឆ្នោត នៅប្រទេសមួយចំនួនឃើញថា គ.ជ.ប នៅប្រទេសកម្ពុជាបានជួយដល់អង្គការជនពិការបានច្រើនជាងប្រទេសទាំងនោះទាក់ទងនឹងការងារបោះឆ្នោត ។ លោកបានបញ្ជាក់ថា នៅថ្ងៃបោះឆ្នោតខាងមុខនេះ អង្គការជនពិការកម្ពុជា នឹងដាក់អ្នកសង្កេតការណ៍ឱ្យចូលរួមសង្កេតមើលដំណើរការ បោះឆ្នោតផងដែរ ។



**ពីឆ្វេងលោក ងិន សៅរ័ត្ន និងសហការីនៃអង្គការជនពិការកម្ពុជា**

ទាក់ទងនឹងការិយាល័យបោះឆ្នោត ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា គ.ជ.ប បានណែនាំដល់មន្ត្រីលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ/ខប) ឱ្យពិចារណា និងពិនិត្យមើលថាតើត្រូវជួយសម្រួលដល់ជនពិការនៅពេលបោះឆ្នោតយ៉ាងដូចម្តេច ។ រីឯសឺមីរ៉ឺងសម្រាប់ឱ្យជនពិការភ្នែកទាំងសងខាងស្ទាបក្នុងការបោះឆ្នោត នោះគឺមាននៅគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ នៅថ្ងៃបោះឆ្នោត ។

ចំពោះការបណ្តុះបណ្តាល ឯកឧត្តម ប្រធាន គ.ជ.ប បានបន្ថែមថា បើអង្គការជនពិការ ចង់ឱ្យ គ.ជ.ប ជួយគឺ គ.ជ.ប អាចជួយបណ្តុះបណ្តាលទាក់ទងនឹងការងារបោះឆ្នោតដល់ជនពិការបាន ។



**រូបថតអនុស្សាវរីយ៍ រវាងមន្ត្រី គ.ជ.ប និងអង្គការជនពិការកម្ពុជា**

ឯកឧត្តម អ៊ឹម សួស្តី បានបញ្ជាក់ថា សូមឱ្យអង្គការជនពិការកម្ពុជាដាក់អ្នកសង្កេតការណ៍ដែលឯករាជ្យ និងសូមជួយវាយតម្លៃការបោះឆ្នោតឱ្យបានត្រឹមត្រូវ និងយុត្តិធម៌ ៕

# បទសម្ភាសន៍ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ជាមួយទូរទស្សន៍ថៃ ប៉ុស្តិ៍លេខ៩ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប (រូបខាងស្តាំ) ផ្តល់បទសម្ភាសន៍ជាមួយទូរទស្សន៍ថៃ

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ជាមួយគ្នានេះដែរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត ដើម្បីឱ្យបានយល់ដឹងអំពីដំណើរការនៃការរៀបចំការបោះឆ្នោតនេះ ។ ការផ្សព្វផ្សាយត្រូវបានធ្វើឡើងតាមរយៈការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ បដា ខិត្តប័ណ្ណ សារព័ត៌មាន និងសេវាកម្មសារជាសំឡេងតាមទូរស័ព្ទដោយឥតគិតថ្លៃ ។ ហើយជាពិសេសទៀត បានជួបជាមួយតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិតាមរយៈការប្រជុំប្រចាំសប្តាហ៍ និងប្រចាំខែ ។

ជាមួយគ្នានេះដែរ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានអនុញ្ញាតឱ្យទូរទស្សន៍ថៃប៉ុស្តិ៍លេខ៩ ធ្វើបទសម្ភាសន៍មួយទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការចុះផ្សាយនូវបទសម្ភាសន៍នេះដូចតទៅ ៖

**សំណួរ : តើការបោះឆ្នោតនៅឆ្នាំនេះ មានអ្វីខុសប្លែកពីការបោះឆ្នោតនៅអាណត្តិមុនៗឬទេ ?**

**ចម្លើយ** : ធម្មតាពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ តែងតែមានការកែលម្អការបោះឆ្នោត

ឱ្យកាន់តែល្អប្រសើរឡើង ។ អញ្ចឹងទេ បើប្រៀបធៀបការរៀបចំនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣នេះ យើងមានការកែលម្អច្រើនជាងការបោះឆ្នោត ឆ្នាំ២០០៨ ៖

យើងកែលម្អការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដែលការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣នេះ បានប្រព្រឹត្តទៅល្អ និងទទួលបានលទ្ធផលល្អ ។ ហើយនៅក្នុងបញ្ជីបោះឆ្នោត បើតាមការត្រួតពិនិត្យបញ្ជីបោះឆ្នោតរបស់ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនឃើញថាបញ្ជីបោះឆ្នោតមានគុណភាពខ្ពស់គឺមានអ្នកបោះឆ្នោតរហូតដល់ជិត ៩៨% ។ ដោយឡែកទាក់ទងនឹងការបោះឆ្នោត ដែលយើងធ្វើនៅពេលខាងមុខនេះ គ.ជ.ប ក៏បានកែលម្អមួយចំនួនទៅលើនីតិវិធីនៃការបោះឆ្នោត ជាពិសេសទៀត ការដាក់/ទទួល និងដោះស្រាយពាក្យបណ្តឹងទាក់ទង នឹងការបោះឆ្នោត ។

ចំណុចថ្មីឆ្នាំនេះ ដែលយើងធ្វើច្រើននោះ គឺការអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត ដើម្បីអំពាវនាវប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតអញ្ជើញទៅបោះឆ្នោត ។ អញ្ចឹងទេ យើងសង្ឃឹមថាការបោះឆ្នោតនៅឆ្នាំ២០១៣នេះ អាច នឹងមានអ្នកបោះឆ្នោតអញ្ជើញទៅបោះឆ្នោតច្រើនជាងការបោះឆ្នោតអាណត្តិមុនៗ ។

**សំណួរ : ទាក់ទងទៅនឹងអ្នកសារព័ត៌មានអន្តរជាតិថា ការបោះឆ្នោតនៅប្រទេសកម្ពុជា មិនយុត្តិធម៌ មិនតម្លាភាព ដំណើរការទៅមិនរលូន តើឯកឧត្តមយល់យ៉ាងណាដែរ ?**

**ចម្លើយ :** ខ្ញុំគិតថា នេះជាសំណួរល្អ ហើយជាធម្មតាក្នុងការរៀបចំការងារផ្សេងៗ ពិសេសការងារបោះឆ្នោត យើងមិនអាចធ្វើឱ្យបានល្អ ១០០% ទេ តែងតែមានការលើកសរសើរ និងទទួលការរិះគន់ទៅលើការរៀបចំការបោះឆ្នោត។ បើយើងប្រៀបធៀបនឹងការវាយតម្លៃទៅលើការរៀបចំការបោះឆ្នោតនៅប្រទេសកម្ពុជាកន្លងមកយើងឃើញថា ជាទូទៅអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានវាយតម្លៃជាវិជ្ជមានអំពីការបោះឆ្នោតនៅប្រទេសកម្ពុជា កាន់តែបានល្អប្រសើរឡើងពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ ។ ក៏ប៉ុន្តែមានមតិរិះគន់ដល់ គ.ជ.ប ដែរថា ការរៀបចំនេះវាពុំទាន់ដល់ស្តង់ដាអន្តរជាតិ។ទោះយ៉ាងណាក៏ដោយ លទ្ធផលនៃការបោះឆ្នោតដែលយើងធ្វើបាននេះ គឺជាសមិទ្ធផលផ្ទាល់របស់កម្ពុជា ទៅតាមសមត្ថភាព និងស្ថានភាពរបស់កម្ពុជាផ្ទាល់ ហើយប្រជាពលរដ្ឋកម្ពុជាអាចទទួលយកបានទាំងអស់គ្នា ។

**សំណួរ : តើមានបញ្ហាអ្វីខ្លះនៃការបោះឆ្នោតដែល គ.ជ.ប បានជួបប្រទះជាញឹកញាប់?**

**ចម្លើយ:** តាមពិតបើនិយាយពីរឿងទូទៅនៅក្នុងការបោះឆ្នោត វាមានស្ទើរគ្រប់បញ្ហាទាំងអស់តែកន្លែងដែលគួរកត់សម្គាល់ខ្លាំងជាងគេ ៖

ទី១ ឈ្មោះនៅលើបញ្ជីបោះឆ្នោត គេថាឈ្មោះនៅលើបញ្ជីបោះឆ្នោតគឺមានឈ្មោះខ្មោច មានឈ្មោះជនបរទេសនៅលើបញ្ជីបោះឆ្នោត ។

ទី២ បញ្ហាដែលកើតឡើងគឺលិខិតបញ្ជាក់អត្តសញ្ញាណ ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត។ មតិមួយចំនួនតែងតែលើកឡើងថា មានការក្លែងបន្លំលិខិតទាំងនេះ ។ ហើយការងារនេះកើតតាំងតែពីអាណត្តិមុនមក ។ សម្រាប់អាណត្តិនេះ គ.ជ.ប ខិតខំដោះស្រាយបញ្ហាទាំង ២ខាងលើហ្នឹង ៖

១- ការងារចុះឈ្មោះបោះឆ្នោត ក្រោយពី គ.ជ.ប បានផ្តល់សុពលភាព មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនរកឃើញថា បញ្ជីបោះឆ្នោត

តទៅទំព័រទី ១៤

# ការងារបោះឆ្នោតត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តែងបើកចំហនូវរាល់កិច្ចការរបស់ខ្លួន ដើម្បីឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាការរៀបចំបទបញ្ជា និងនីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២និង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ឆ្នាំ២០១៣។គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ភាគីពាក់ព័ន្ធបានចូលរួមផ្តល់មតិយោបល់សំដៅធ្វើយ៉ាងណាឱ្យបទបញ្ជា និងនីតិវិធីនេះ កាន់តែមានភាពល្អប្រសើរឡើង ត្រឹមត្រូវ យុត្តិធម៌ និង តម្លាភាព ។

ដើម្បីឱ្យសាធារណជនបានយល់ដឹងកាន់តែច្បាស់ និងឆ្លើយតបទៅនឹងមតិរិះគន់មួយចំនួនទាក់ទងនឹងដំណើរការបោះឆ្នោត គ.ជ.ប សូមធ្វើការស្រាយបំភ្លឺដូចខាងក្រោម ។

I- **អំពីបញ្ជីបោះឆ្នោត** :

ក្នុងបំណងរៀបចំបញ្ជីបោះឆ្នោតមួយឱ្យកាន់តែមានភាពសុក្រឹត និងប្រកបដោយគុណភាពថែមទៀតនោះ គ.ជ.ប បានដាក់ចេញនូវវិធានការ ១៥ ចំណុច ហើយបានអនុវត្តតាំងពីមុនពេលចាប់ផ្តើម និងក្នុងអំឡុងពេលអនុវត្តជាក់ស្តែង ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ ។ វិធានការនេះរួមមាន ៖

១- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ផលិតស្ប៉ូតវីដេអូស្តីពីនីតិវិធី និងការអនុវត្តការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ដែលស្ប៉ូតនេះ បានចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងចែកផ្សាយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

២- សហការជាមួយក្រសួងមហាផ្ទៃចេញសេចក្តីណែនាំដល់អាជ្ញាធរពាក់ព័ន្ធឱ្យយកចិត្តទុកដាក់គាំទ្រ និងបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនបំពេញការងារប្រកបដោយប្រសិទ្ធភាព និងបានកែប្រែពេលម៉ោងបំពេញការងារ ពីធ្វើការពីម៉ោង ៧:០០នាទី ដល់ម៉ោង ១៧:៣០នាទី មកជាការធ្វើការងារពីរពេលវិញ គឺពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងរសៀលពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០ នាទី ។

៣- សហការជាមួយក្រសួងមហាផ្ទៃចេញសេចក្តីណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យធ្វើការប្រជុំប្រចាំសប្តាហ៍ ដើម្បីត្រួតពិនិត្យអំពី វឌ្ឍនភាព បញ្ហាប្រឈមនានា ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សំដៅជម្រុញដំណើរការនេះឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ។

៤- ធ្វើលិខិតទៅអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីស្នើសុំកិច្ចសហការគាំទ្រដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងស្នើសុំកិច្ចសហការក្នុងការអប់រំផ្សព្វផ្សាយ និងលើកទឹកចិត្តមន្ត្រីបុគ្គលិកក្រោមឱវាទ និងប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ឱ្យចុះឈ្មោះបោះឆ្នោត ឬលុបឈ្មោះសមាជិកគ្រួសារដែលស្លាប់ ឬផ្លាស់ចេញ ចេញពីបញ្ជីបោះឆ្នោត ។

ដោយមានកិច្ចសហការពីគណៈអភិបាលរាជធានី ខេត្ត គ.ជ.ប បានចុះផ្សព្វផ្សាយខ្លឹមសារនេះ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន នៅតាមរាជធានី ខេត្តមួយចំនួន ។

៥- ផ្ញើលិខិតទៅគ្រប់ក្រសួងស្ថាប័នរដ្ឋដើម្បីស្នើសុំកិច្ចសហការក្នុងការអំពាវនាវ និងលើកទឹកចិត្តមន្ត្រីបុគ្គលិកក្រោមឱវាទឱ្យទៅចុះឈ្មោះបោះឆ្នោត ឬទៅលុបឈ្មោះស្ទួនចេញពីបញ្ជីបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ និងឆ្នាំបន្តបន្ទាប់ ។

៦- ផ្ញើលិខិតទៅគ្រប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អំពាវនាវឱ្យចូលរួមក្នុងការអប់រំអ្នកបោះឆ្នោត និងសាធារណជន អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១២ និងឆ្នាំបន្តបន្ទាប់ ។

៧- រៀបចំកិច្ចប្រជុំជាមួយតំណាងក្រសួង និងស្ថាប័នរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងគោលបំណង ៖

- បំផុសយុវជនទើបគ្រប់អាយុបោះឆ្នោត អ្នកមិនធ្លាប់បានចុះឈ្មោះបោះឆ្នោត អ្នកផ្លាស់ប្តូរទីលំនៅចូលថ្មីឱ្យទៅចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ តាមការជូនដំណឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

- បំផុសមន្ត្រីតាមក្រសួងមន្ទីររបស់រដ្ឋឱ្យទៅមើលឈ្មោះ និងកែតម្រូវឈ្មោះ ក្នុងករណីមានខុសទិន្នន័យ ។

- បំផុសមន្ត្រី និងប្រជាពលរដ្ឋដែលមានឈ្មោះលើសពីមួយក្នុងបញ្ជីបោះឆ្នោតឱ្យទៅរាយការណ៍ជូនស្មៀនឃុំ សង្កាត់ ដើម្បីលុបឈ្មោះលើសចេញពីបញ្ជីបោះឆ្នោត ដោយទុកឈ្មោះតែមួយនៅកន្លែងដែលត្រូវបោះឆ្នោត ។

៨- ដើម្បីលុបឈ្មោះស្ទួនក្នុងឃុំ សង្កាត់ មជ្ឈមណ្ឌលកុំព្យូទ័រនៃ គ.ជ.ប បានរកឃើញឈ្មោះស្ទួនមួយចំនួន ហើយបានស្រង់ឈ្មោះស្ទួនទាំងនោះចូលក្នុងទម្រង់ **១០២៦** រួចបញ្ជូនទៅឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីធ្វើការស្រាវជ្រាវបន្តមុននឹងលុបឈ្មោះទាំងនោះចេញពីបញ្ជីបោះឆ្នោត ។ ម្យ៉ាងទៀតក្នុងប្រតិបត្តិការបញ្ចូលឈ្មោះអ្នកបោះឆ្នោតនៅមជ្ឈមណ្ឌលកុំព្យូទ័រ គ.ជ.ប បានបង្កើនការយកចិត្តទុកដាក់លើការបញ្ចូលទិន្នន័យទ្វេដង ក្នុងការបញ្ចូលឈ្មោះ លុបឈ្មោះនិងកែតម្រូវទិន្នន័យ សំដៅធ្វើយ៉ាងណា ឱ្យបញ្ជីបោះឆ្នោតកាន់តែមានភាពសុក្រឹត ។

៩- បង្ហោះបញ្ជីបោះឆ្នោតចុងក្រោយលើគេហទំព័រ www.voterlist.org.kh ដើម្បីងាយស្រួលក្នុងការស្វែងរកឈ្មោះ ឬផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោត ។

១០- ចេញសេចក្តីណែនាំ ឱ្យបង្កើតមជ្ឈមណ្ឌល ស្វែងរកឈ្មោះអ្នកបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោតតាមប្រព័ន្ធអ៊ីនធើណែតតាមគេហទំព័រ www.voterlist.org.kh នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងនៅតាមមន្ទីរនានាចំណុះរាជធានី ខេត្ត និងមានទូរស័ព្ទ (Hotline) ចំនួន ៥ ខ្សែសម្រាប់ឱ្យសាធារណជនទំនាក់ទំនងស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត។

១១- ផ្ញើលិខិតទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំអន្តរាគមន៍ដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត បង្កលក្ខណៈដល់សាលាឃុំ សង្កាត់នៃរាជធានី ខេត្តណាដែលមានលទ្ធភាព និងសមត្ថភាពអាចប្រើប្រាស់កុំព្យូទ័រ ជាមួយនឹងអ៊ីនធើណែត សំដៅពង្រឹងគុណភាព បញ្ជីបោះឆ្នោត

និងបម្រើសេវាជូនប្រជាពលរដ្ឋក្នុងការស្វែងរកឈ្មោះ និងទិន្នន័យក្នុងពេលពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោត ។

១២- ធ្វើលិខិតទៅក្រសួងធម្មការ និងសាសនា ដើម្បីឱ្យជួយអន្តរាគមន៍គ្រប់ទីវត្តអារាម ក្នុងពិធីដាក់បិណ្ឌជួយផ្សព្វផ្សាយនិងផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។

១៣- សមាជិក សមាជិកា គ.ជ.ប និងអគ្គលេខាធិការ អគ្គលេខាធិការរង គ.ជ.ប ចុះតាមឃុំ សង្កាត់នៅរាជធានី ខេត្តមួយចំនួន ដើម្បីពិនិត្យមើលការអនុវត្តជាក់ស្ដែងរបស់ស្មៀនឃុំ សង្កាត់ ។

១៤- រៀបចំកិច្ចប្រជុំជាមួយ តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយប្រចាំសប្ដាហ៍ ដើម្បីជូនព័ត៌មាន ផ្លាស់ប្ដូរយោបល់ព័ត៌មាន អំពីការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតនិងអំពាវនាវឱ្យចូលរួមសហការតាមតួនាទី ដើម្បីអប់រំប្រជាពលរដ្ឋឱ្យចូលរួមក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ពិសេសឱ្យទៅពិនិត្យមើលបញ្ជីបោះឆ្នោតដំបូងដែលមានបិទផ្សាយព្រមគ្នា នៅតាមសាលាឃុំ សង្កាត់ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ។

១៥- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជូនព័ត៌មាន និងសម្របសម្រួលឱ្យតំណាងស្ថានទូតប្រចាំនៅកម្ពុជា ចុះពិនិត្យមើលសកម្មភាពចុះឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់ក្នុងរាជធានីភ្នំពេញ និងខេត្ត កណ្ដាល ។

ការពិតការរៀបចំបញ្ជីបោះឆ្នោតដោយគ.ជ.ប ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំនេះ គឺមិនអាចធ្វើឱ្យបញ្ជីបោះឆ្នោតមានភាពសុក្រឹត ១០០% ទេ ព្រោះថាការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តតាមគោលការណ៍មិនចាប់បង្ខំ។

តាមការស្រាវជ្រាវ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតអចិន្ត្រៃយ៍ តែងតែមានភាពប៉ោងឡើងជារៀងរាល់ឆ្នាំ ដោយការខកខានលុបឈ្មោះអ្នកស្លាប់ អ្នកបាត់បង់សិទ្ធិ អ្នកផ្លាស់ទីលំនៅចេញ និងឈ្មោះស្ទួនចេញពីបញ្ជីបោះឆ្នោត ពីព្រោះ គ.ជ.ប មិនអាចលុបឈ្មោះប្រជាពលរដ្ឋណាម្នាក់ ចេញពីបញ្ជីបោះឆ្នោតដោយគ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់បានឡើយ ។ មិនថាតែនៅប្រទេសកម្ពុជាយើងទេប្រទេសណាក៏ដោយ ឱ្យតែអនុវត្តតាមប្រព័ន្ធបែបនេះ គឺប្រឈមនឹងបញ្ហានេះដូចគ្នា។

ទោះយ៉ាងណាក៏ដោយ ពីមួយឆ្នាំទៅមួយឆ្នាំ គ.ជ.ប ខិតខំប្រឹងប្រែងបង្កើតយន្តការ ដើម្បីលុបឈ្មោះប៉ោងក្នុងបញ្ជីបោះឆ្នោត ដូចជា ការជម្រុញឱ្យប្រជាពលរដ្ឋដែលមានឈ្មោះលើសពីមួយកន្លែងនៅក្នុងបញ្ជីបោះឆ្នោតឱ្យទៅលុបឈ្មោះលើសចេញ ដោយរក្សាទុកឈ្មោះតែមួយក្នុងបញ្ជីដែលខ្លួនត្រូវបោះឆ្នោត ណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ស្រង់ឈ្មោះស្ទួន ដើម្បីត្រៀមលុបចេញពីបញ្ជីបោះឆ្នោតនៅក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ជាលទ្ធផល គ.ជ.ប ទទួលបានលទ្ធផលកាន់តែល្អប្រសើរឡើងជាបន្តបន្ទាប់។

សរុបមកលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ គឺមានឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចំនួន ៩.៦៧៥.៤៥៣នាក់ និងមានការិយាល័យបោះឆ្នោត ចំនួន ១៩.០០៩ ការិយាល័យ ។ បញ្ជីបោះឆ្នោតនេះត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ ។ ថ្មីៗនេះអង្គការមិនមែនរដ្ឋាភិបាល មួយបានធ្វើសវនកម្មលើបញ្ជីបោះឆ្នោតនេះ ហើយបានវាយតម្លៃថា អ្នកមានសិទ្ធិបោះឆ្នោតមានឈ្មោះក្នុងបញ្ជីបោះ ឆ្នោតចំនួនជិត ៩៨% ។

II- **អំពីការជ្រើសរើសមន្ត្រីបោះឆ្នោត** :

គ.ជ.ប បើកទូលាយ មិនរើសអើងសម្រាប់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទស្របតាមមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញដែលចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម" ។ ម្យ៉ាងទៀត តាមច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមាត្រា១២ចែងថា" គ.ជ.បជាអង្គការឯករាជ្យ និងអព្យាក្រឹត ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។ សមាជិកទាំងឡាយនៃ គ.ជ.ប និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀង ក្នុងការអនុវត្តការងារបោះឆ្នោត" ។



យុវជនដែលមកសម្ភាសន៍ចូលបម្រើការងារនៅទីស្តីការ គ.ជ.ប

គ.ជ.ប បានរៀបចំជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោត តាមសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងចំណុចទី៣ និងទី៤ នៃមាត្រា ១៦ថ្មី ១៨ថ្មី ២០ថ្មី និងមាត្រា ២២ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងរបស់គ.ជ.ប។ ដូចនេះអនុសាសន៍ទាំងឡាយណា ដែលសុំបង្កើតគណៈកម្មការជ្រើសរើសផ្សេងពីនេះ ពុំត្រឹមត្រូវតាមច្បាប់ឡើយ ។

III- **អំពីមន្ត្រីរាជការស៊ីវិល និង កម្លាំងប្រដាប់អាវុធ ធ្វើសកម្មភាពឃោសនាបោះឆ្នោត** :

មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីតុលាការ ក៏ជាពលរដ្ឋដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់ប្រទេសជាតិ" ។ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មាត្រា ៣៧ ហាមមន្ត្រីរាជការប្រើប្រាស់មុខងាររបស់ខ្លួន និងការប្រើប្រាស់សម្ភាររបស់រដ្ឋ ដើម្បីបម្រើសកម្មភាពគណបក្សនយោបាយ ។ ដូចនេះក្រៅពីពេលបំពេញមុខងារ មន្ត្រីរាជការមានសិទ្ធិដូចប្រជាពលរដ្ឋដទៃទៀតដែរ។

IV- **អំពីការប្រើប្រាស់ធនធាន និងមធ្យោបាយរដ្ឋក្នុងពេលឃោសនាបោះឆ្នោត** :

ច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី បានហាមមិនឱ្យយកធនធានរដ្ឋធ្វើជាមធ្យោបាយក្នុងការធ្វើសកម្មភាពឃោសនាគាំទ្រគណបក្សឡើយ ។ គ.ជ.ប បានកំណត់ក្នុងបទបញ្ជា និងនីតិវិធីចំពោះមធ្យោបាយដឹកជញ្ជូនដែលមានស្លាកលេខរាជការរដ្ឋ ន.ប ខ.ម រាជរដ្ឋាភិបាល មិនឱ្យប្រើប្រាស់ធ្វើសកម្មភាពឃោសនាបោះឆ្នោត។ ចំពោះការហាមឃាត់ការប្រើប្រាស់យានយន្ត ឬទោចក្រយានដែលគ្មានស្លាកលេខ ធ្វើជាមធ្យោបាយក្នុងសកម្មភាពឃោសនា មិនមែនជាសមត្ថកិច្ចរបស់ គ.ជ.ប ទេ។ ប៉ុន្តែ គ.ជ.ប អំពាវនាវឱ្យការប្រើប្រាស់យានយន្តក្នុងការឃោសនាបោះឆ្នោត ត្រូវគោរពច្បាប់ចរាចរណ៍។ ជាក់ស្តែងកន្លងមក ករណីមានពាក្យ

បណ្តឹង ស្តីពីការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ ក្នុងពេលឃោសនាបោះឆ្នោត គ.ជ.ប តែងធ្វើការដោះស្រាយព្រមទាំងដាក់ពិន័យទៅលើអ្នករំលោភបំពានលើការហាមឃាត់នេះផងដែរ ។

គ.ជ.ប បាននិងកំពុងរៀបចំស្ប៉ុតអប់រំក្នុងគោលដៅអប់រំផ្សព្វផ្សាយ អំពីការហាមប្រើប្រាស់នូវធនធានរដ្ឋក្នុងពេលឃោសនាបោះឆ្នោត។

V- **ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋក្នុងពេលឃោសនាបោះឆ្នោត** :

- ក្នុងពេលឃោសនាបោះឆ្នោត កន្លងមក គ.ជ.ប បានរៀបចំកម្មវិធីគោលនយោបាយ គណបក្សដោយចាក់ផ្សាយក្នុងមួយថ្ងៃយ៉ាងតិច ៦ ម៉ោង តាមទូរទស្សន៍ចំនួន ២ ម៉ោង វិទ្យុ FM ចំនួន ២ ម៉ោង និងវិទ្យុ AM ចំនួន ២ម៉ោង ។

- ពេលវេលានៃការចាក់ផ្សាយត្រូវបានសម្របសម្រួលតាមពេលវេលាដ៏សមស្របមួយ។

- ក្រៅពីម៉ោងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្ស គ.ជ.ប បានផ្សព្វផ្សាយស្ប៉ុតអប់រំកម្មវិធីស្វែងយល់អំពីការបោះឆ្នោតផងដែរ ។

- កន្លងមក គ.ជ.ប មានគោលការណ៍ដាច់ដោយឡែក ដោយផ្តល់ឱកាសដល់គណបក្សនយោបាយទិញម៉ោងផ្សាយពីវិទ្យុ និងទូរទស្សន៍ឯកជនដោយឈរលើគោលការណ៍ស្មើភាព ។

- គ.ជ.ប មានគោលការណ៍ហាមគណបក្សនយោបាយទិញម៉ោងផ្សាយផ្តាច់មុខ ។/

តមកពីទំព័រទី ៨ **ការចុះហត្ថលេខាលើ...**

សារខ្លីៗ (Short Message Service) ។ ហើយក្នុងនោះក៏បានចែងផងដែរថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគឺជាស្ថាប័នឯករាជ្យនិងអព្យាក្រឹត ដែលទទួលខុសត្រូវក្នុងការចុះឈ្មោះបោះឆ្នោត និងគ្រប់គ្រងចាត់ចែងការបោះឆ្នោតនៅកម្ពុជា ។/

តមកពីទំព័រទី ៩ **បទសម្ភាសន៍ឯកឧត្តម ទេព នីថា...**

មានកម្រិតល្អដែលមានឈ្មោះអ្នកបោះឆ្នោតរហូតដល់ ៩៨% ឯណោះ ។

២- ទាក់ទងនឹងលិខិតបញ្ជាក់អត្តសញ្ញាណដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត ប្រជាពលរដ្ឋដែលគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីបោះឆ្នោត



**ការធ្វើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត**

អាចនាំសាក្សី ២នាក់ ទៅជួបមេឃុំ ចៅសង្កាត់ ដើម្បីសុំលិខិតនោះមកចុះឈ្មោះបោះឆ្នោត ហើយគាត់អាចប្រើប្រាស់លិខិតនោះបោះឆ្នោតបាន ។ ការងារនេះ គ.ជ.ប បានសហការជាមួយក្រសួងមហាផ្ទៃរៀតបន្តឹងក្នុងការចេញលិខិតនេះ គឺត្រូវឱ្យមានរបាយការណ៍បិទផ្សាយជាសាធារណៈឱ្យបានដឹងថាការចេញលិខិតបានប៉ុន្មាននៅពេលចុះឈ្មោះបោះឆ្នោត ហើយចេញបានប៉ុន្មានទៀតនៅពេលបោះឆ្នោត។ ការងារទាំងអស់នេះ គ.ជ.ប ឱ្យគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍អាចពិនិត្យឯកសារ ដែលមេឃុំ ចៅសង្កាត់ចេញលិខិតនេះនៅឃុំសង្កាត់ទៀត ។ គ.ជ.ប បានដោះស្រាយបញ្ហាទាំងពីរនេះ សម្រាប់ការបោះឆ្នោត ។

**សំណួរ : តើព្រះសង្ឃអាចបោះឆ្នោតបានឬទេ ?**

**ចម្លើយ :** *អាចបោះឆ្នោតបាន ។*

**សំណួរ : ចុះជនបរទេសដែលបានសញ្ជាតិខ្មែរអាចបោះឆ្នោតបានឬទេ ?**

**ចម្លើយ :** *ឱ្យតែអ្នកមានសញ្ជាតិខ្មែរអាចបោះឆ្នោតបានទាំងអស់ ។*

*ការហាមឃាត់មិនឱ្យបោះឆ្នោតគឺ ៖*

*- អ្នកដែលមានទោសជាប់ពន្ធនាគារ*

*- អ្នកដែលបាត់បង់សិទ្ធិបោះឆ្នោត ដោយសារគាត់មានទោសត្រូវបានគេដកហូតសិទ្ធិបោះឆ្នោត*

*- អ្នកវិកលចរិកដែលមានឯកសារបញ្ជាក់ត្រឹមត្រូវ ។*

**សំណួរ : ពាក់ព័ន្ធជាមួយលោក សម រង្ស៊ី ដែលត្រូវមានទោស តើគាត់អាចត្រឡប់មកចូលរួមបោះឆ្នោតអាណត្តិនេះបានដែរ ឬទេ ?**

**ចម្លើយ:** *បើតាមច្បាប់មិនអាចបានទេ ពីព្រោះឈ្មោះរបស់គាត់ត្រូវបានលុបចេញពីបញ្ជីបោះឆ្នោត ហើយដោយសារគាត់មានទោស ហើយមានសាលក្រមជាស្ថាពរពីតុលាការនៅក្នុងឆ្នាំ២០១២ កន្លងមក ។ ដូចនេះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺគាត់មិនអាចឈរឈ្មោះជាបេក្ខជនបានទេ ហើយក៏មិនអាចបោះឆ្នោតបានដែរ ។*

**សំណួរ : តើឈ្មោះរបស់លោក សម រង្ស៊ី លុបទៅរហូតឬ?**

**ចម្លើយ :** *នៅពេលដែលគាត់អនុវត្តទោសចប់អស់ហើយគាត់អាចចុះឈ្មោះបោះឆ្នោតវិញបាន ។ តែការចុះឈ្មោះនេះយើងមិនមែនចុះឈ្មោះរាល់ថ្ងៃទេ។ នៅប្រទេសកម្ពុជា គឺមួយឆ្នាំយើងចុះឈ្មោះម្តង ។ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតនៅប្រទេសកម្ពុជា គឺចុះឈ្មោះដោយស្ម័គ្រចិត្ត ប្រជាពលរដ្ឋត្រូវទៅចុះឈ្មោះដោយខ្លួនឯង ។ បញ្ជីបោះឆ្នោតប្រចាំឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពមួយឆ្នាំម្តង។ ឧបមាថាឆ្នាំបោះឆ្នោតនេះ យើងចុះឈ្មោះពី ខែកញ្ញារហូតដល់ ខែតុលា ឆ្នាំ២០១២ ។ ដូចនេះការចុះឈ្មោះនេះមិនអាចចុះឈ្មោះមួយឆ្នាំ៣៦៥ថ្ងៃបានទេ ។ អញ្ចឹងទោះបីគាត់រួចទោសក្តី ប៉ុន្តែនៅឆ្នាំដែលបោះឆ្នោតនេះគាត់មិនចុះឈ្មោះបោះឆ្នោតបាន គាត់មិនអាចបោះឆ្នោតបាន ក៏មិនអាចឈរឈ្មោះបោះឆ្នោតបានដែរ ៕*

---


## ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

### អ្នកគ្រប់គ្រង

លោក មៃ សារី

### ក្រុមនិពន្ធ

លោក មិន ពុធជេដ្ឋាវណ្ណ លោក សុខ លាត

កញ្ញា អេង រដ្ឋា

### កំណែអក្ខរាវិរុទ្ធ

អ្នកស្រី ទិន សាវត្ថី

### អ្នកថតរូប

លោក សាក់ ប៉ូរិន លោក អ៊ុក សំបូរ

លោក សំ បុក

### ក្រាហ្វិកកុំព្យូទ័រ

លោក ប៉េង រតនៈ លោក មាស សុធារ៉ា

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៣

## ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ ឆ្នាំ២០១៣

## ( វិសោធនកម្ម )

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០១២ ដោយ គ.ជ.ប | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ |
| ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន | ថ្ងៃទី២៩ ខែមេសា - ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០១៣ |
| ការប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះបញ្ជីគណបក្សទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ ថ្ងៃ | ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ ថ្ងៃ | ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត | ថ្ងៃទី ០១ - ២៥ ខែ មិថុនា ឆ្នាំ២០១៣ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតនៅ គឃ/សប | ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ |
| ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ តាមមណ្ឌលរាជធានី ខេត្ត | ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី ២៧ ខែមិថុនា - ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០១៣ |
| ការចុះឈ្មោះតំណាងគណបក្សនយោបាយ | ថ្ងៃទី២៨ ខែ មិថុនា - ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០១៣ |
| ការបិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីទីតាំង នៅការិយាល័យបោះឆ្នោត និងនៅ គឃ/សប | ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៣ |
| ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលបឋមនៅការិយាល័យបោះឆ្នោត | ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ |
| ការប្តឹងតវ៉ាទៅ គឃ/សប អំពីលទ្ធផលនៃការបោះឆ្នោត ឬភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោត | ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣<br>( *យ៉ាងយូរត្រឹមម៉ោង ១១:៣០ នាទី* ) |
| គឃ/សប សម្រេចលើបណ្តឹង ត្រួតពិនិត្យ បូកសរុបលទ្ធផល ធ្វើកំណត់ហេតុ និងបិទផ្សាយកំណត់ហេតុ | ថ្ងៃទី ២៩ - ៣០ ខែកក្កដា ឆ្នាំ ២០១៣ |
| ការប្តឹងតវ៉ាទៅ គធ/ឧប ក្នុងរយៈពេលយ៉ាងយូរ ២ ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គឃ/សប | ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយ គធ/ឧប ក្នុងរយៈពេលយ៉ាងយូរ ៣ ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្តឹង | ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គធ/ឧប | ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្តឹង | ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការប្រកាសលទ្ធផលបណ្តោះអាសន្នដោយ គ.ជ.ប ( ករណីគ្មានការបោះឆ្នោតសាជាថ្មី ) | ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៣ |
| ការប្តឹងតវ៉ាទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីលទ្ធផលបណ្តោះអាសន្នក្នុងរយៈពេល<br>យ៉ាងយូរ ៧២ ម៉ោង | ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤៨ ម៉ោង បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ ម៉ោង បន្ទាប់ពីការបដិសេធរបស់ គ.ជ.ប | ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ២០ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការបោះឆ្នោតសាជាថ្មី ( ប្រសិនបើមាន ) | ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៣ ( ថ្ងៃចុងក្រោយ ) |
| ការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោត ( តាមករណីគ្មាន ឬមានបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី ) | ថ្ងៃទី១៤ ខែសីហា - ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៣ |